# ១៦_រឿង វត្តវិហារសួរ នៅខេត្តកណ្ដាល

វត្តវិហារសួរ ជាបូជនីយដ្ឋានដ៏សក្តិសិទ្ធិមួយ ឮកិត្តិនាមពេញប្រទេសកម្ពុជាតាំងពីអតីតកាល រហូតមកដល់បច្ចុប្បន្នកាលនេះ អ្នកផងសឹងបានជ្រាបជាច្រើន ។ រៀងរាល់ឆ្នាំក្នុងមួយឆ្នាំៗ តែងមានមហាជនរាប់ពាន់នាក់ ទៅបូជា បែរបន់តាមប្រាថ្នាផ្សេងៗ ទាំងព្រះរាជាព្រះរាជវង្សានុវង្ស នាម៉ឺនសព្វមុខមន្ត្រី ក៏បានស្ដេចយាង តែងអញ្ជើញទៅបូជាបួងសួងនៅទីនោះដែរ ។

វត្តវិហារសួរ មានដើមកំណើតជាព្រះរាជទ្រព្យ ដែលព្រះរាជាបក្សីចាំក្រុងទ្រង់កសាងទុកជាអនុស្សាវរីយ៍ត្រង់ទីដែលតាគហេ កើនព្រះអង្គឡើងឋានសួគ៌ សឹងមានចែងទុកជាប្រវត្តិនៃព្រះវិហារនោះដូចតទៅ : តាមរបាក្សត្រដែលមានចារិកទុកមកក្នុងព្រះរាជវង្សសាវតាប្រទេសកម្ពុជាថា : "វត្តព្រះវិហារសួរ កើតឡើងក្នុងរជ្ជកាលទី១៩ រជ្ជកាលព្រះបាទបក្សីចាំក្រុង ជាព្រះរាជាប្រទេសកម្ពុជា គង់នៅនគរវត្ត ក្នុងព.ស.រវាង១៥៧២ គ.ស.រវាង១០២៨ ឬ២៩ ព្រះអង្គបានផ្ដើមកសាងទុកជាអនុស្សាវរីយ៍រំលឹកដល់ពេលព្រះអង្គរត់គេចពីកងទ័ព ជាមួយតាគហេ" ។

រឿងរ៉ាវដើមហេតុនាំឱ្យមានរត់គេចពីកងទ័ពនេះ មានដំណាលថា កាលដែលព្រះបាទចក្រពត្រ ព្រះរាជាប្រទេសកម្ពុជារជ្ជកាលទី១៦ ទ្រង់ព្រះទីវង្គត់ទៅ បុរសម្នាក់ឈ្មោះដំបងគ្រញូងមានមហិទ្ធិឫទ្ធិខ្លាំងពូកែ បានសោយរាជជា រជ្ជកាលទី១៧ ឡើងឱ្យបង្គាប់ឱ្យធ្វើគតព្រះរាជវង្សានុវង្សមុន ។

កាលនោះមានព្រះម្នាងម្នាក់ទ្រង់ព្រះគិតពុំទាន់គ្រប់ខែ ភាសខ្លួនជារាស្ត្រសាមញ្ញចេញទៅស្រុកក្រៅ សំណាក់ជាមួយតាគហេ និង យាយលាក់ ជាស្វាមីភរិយា ។ លុះព្រះគិតគ្រប់ខែ១០ ក៏សម្ភពព្រះរាជបុត្រាមួយព្រះអង្គប្រកបដោយលក្ខណៈល្អមានលាយលក្ខណ៍កងចក្រនៅបាតព្រះហស្ត និងបាតព្រះបាទ។ តាគហេ និង យាយលាក់ ស្រលាញ់ណាស់ថ្នាក់ថ្នមដូចកូនបង្កើត។

ថ្ងៃមួយតាយាយ និងព្រះម្នាងទៅច្រូតស្រូវ បានផ្ដេកព្រះរាជកុមារក្រោមម្លប់ឈើមួយដើម។ លុះកំដៅថ្ងៃចាំងមកត្រូវព្រះរាជកុមារមានបក្សីមួយមកកាងស្លាបក្រុងបាំងពីលើមិនឱ្យត្រូវថ្ងៃ។

តាគហេស្មានថាសត្វចឹកចៅរត់ទៅមើល បក្សីនោះហើរទៅបាត់ទៅ ។ តាគហេនឹកសរសើរថា កូននេះមានបុណ្យអស្ចារ្យណាស់ក៏ថ្វាយព្រះនាមថា "បក្សីចាំក្រុង" ។

តមកកាលពីព្រះបាទព្រហ្មកិល (ពញាក្រែក) រជ្ជកាលទី១៨ ទ្រង់សោយរាជ្យឡើងទ្រង់បានជ្រាបទំនាយតាមពួកហោរ៉ាទាយថា "មានអ្នកមានបុណ្យកើតក្នុងត្រកូលក្សត្រ បានព្រះជន្ម៧ឆ្នាំហើយ ភាសនឹខ្លួនជាប្រជារាស្ត្រក្នុងអាណាចក្រនេះ អ្នកមានបុណ្យនោះមានកងចក្រនៅបាតដៃបាតជើង" ទ្រង់ក៏យកក្មេងៗអាយុ៧ឆ្នាំ ដែលមាននៅក្នុងព្រះនគរទាំងប៉ុន្មានមកផ្ទិតដៃនៅលើម្សៅក្នុងចង្អេរ ដើម្បីទ្រង់ពិនិត្យរកកងចក្រ។ តាគហេ ភ័យក៏ពរបក្សីចាំក្រុងរត់ចេញ ។ព្រះរាជាទ្រង់ចាត់ទ័ពតាមចាប់ ។

ហេតុតែបុណ្យបរមីបក្សីចាំក្រុង កងទ័ពដេញតាមពុំទាន់ រកពុំឃើញ។ តាគហេបានបញ្ចិះបក្សីចាំក្រុងលើស្មា

ដើរកាត់ព្រៃទៅផ្ទះគាត់ ដល់ផ្ទះហើយគាត់ទូលបក្សីចាំក្រុងថា "បាគង់នៅទីនេះចុះ ចាំតាទៅកៀរគោបញ្ចូលក្រោលសិន"។ ហើយគាត់ចោលដំបងដេញគោ ដំបងបាត់ក្នុងទឹកអូររកពុំឃើញ បានជាអូរនោះឈ្មោះថា "អូរដំបង" នៅក្នុងខេត្តបាត់ដំបងសព្វថ្ងៃនេះ។

បន្ទាប់ពីនេះ តាគហេ ពរបក្សីចាំក្រុងរត់កាត់ព្រៃទៅដល់ទួលមួយមានដើមរលួសម្លប់ត្រឈៃល្អ ក៏ឈប់សំរាកដេកនៅទីនោះបានជាទីនោះហៅថា "ភូមិរលួស" នៅក្នុងស្រុកសូត្រនិគម ខេត្តសៀមរាប សព្វថ្ងៃនេះ ។ តពីនោះតាគហេ និងបក្សីចាំក្រុង ដោយសារទូកគេឆ្លងកាត់ទីទំនាបទឹកមកដល់ខេត្តជើងព្រៃ កងទ័ពលើកតាមមកជិតទាន់ តាគហេក៏នាំបក្សីចាំក្រុងវេះពួនក្នុងព្រៃ វេលាយប់ព្រៃនោះមានមូសច្រើនបក្សីចាំក្រុងបួងសួងថា "បើខ្ញុំមានបុណ្យ សូមកុំឱ្យមានមូសនៅទីនេះ" ដោយអនុភាពព្រះរាជកុមារ មូសក៏បាត់អស់ទៅ ទើបទីនោះមានឈ្មោះថា "ទួលគហេ"ក្នុងតំបន់រកាកោងស្រុកមុខកំពូលខេត្តកណ្ដាលសព្វថ្ងៃនេះ។

លុះព្រឹកឡើង តាគហេ ក៏នាំបក្សីចាំក្រុងរត់ទៅទៀត ដល់មាត់ទន្លេប្រុងនិងឆ្លងទៅត្រើយខាងត្បូងតែរកទូកឆ្លងគ្មានបក្សីចាំក្រុងផ្សងបារមីថា "បើខ្ញុំត្រូវបានសោយរាជ្យហើយបានទំនុកបំរុងពុទ្ធសាសនាមែន សូមឱ្យដើមរការនៅត្រើយខាងជើងកោងទៅដើមល្វានៅត្រោយខាងត្បូងទេរមក" ។ ដើមឈើទាំងពីរនោះក៏កោងទៅទេមក ដូចប្រណិធាន ។ តាគហេក៏ពរបក្សីចាំក្រុងឆ្លងតាមឈើទាំងពីរនោះរួចទៅ ដើមទាំងពីរក៏ឡើងដូចដើមវិញ ទើបត្រើយខាងជើងមានឈ្មោះថា"រការកោង"នៅស្រុកមុខកំពូលខេត្តកណ្ដាល។

ត្រើយខាងត្បូងមានឈ្មោះថា"ល្វាទេ"នៅស្រុកស្រីសន្ធរខេត្តកំពង់ចាមសព្វថ្ងៃនេះ។

លុះតាគហេនាំរត់ទៅត្រើយខាងត្បូង ដល់ទួលមួយប្របឆ្នេរបឹងបានកាប់មែកជ្រៃដោតធ្វើសម្របសំរាប់ស្រប់សំរាកកំលាំងនៅទីនោះបក្សីចាំក្រុងក៏និទ្រាលក់ក្រោមម្លប់សម្របនោះ។

កំពុងតែលក់ស្រួលស្រាប់តែហ្វូងសត្វត្រដក់ រនៀល ទង់ ជាច្រើនដែលចុះរកស៊ីក្នុងបឹងនោះ វាផ្អើលអ៊ូរឡើងឮសន្ធឹកជាខ្លាំង តាគហេឮសព្ទនោះស្មានថាកងទ័ព ក៏ស្ទុះតើនព្រះរាជកុមារឡើងសួរថា "នែចៅ! ឮសូរអ្វីខ្លាំងម្ល៉េះ" ។ ព្រះរាជកុមារតើនឡើងភ័យណាស់ស្មានថាកងទ័ព ក៏ស្ទុះឡើងមែកជ្រៃដែលដោតធ្វើសម្របនោះឈរមើលគ្រប់ទិសទី មិនឃើញកងទ័ព ឃើញតែសត្វហើរដេរដាស់ក៏បាត់ភ័យទៅវិញ មែកឈើនោះរស់នៅរៀងដរាបមក នៅខាងត្បូងវត្តវិហារសួរសព្វថ្ងៃនេះ ។ លំដាប់ពីនោះ តាគហេនាំបក្សីចាំក្រុងរត់ឆ្លងទន្លេដោយទូកទៅត្រើយខាងលិច ទៅពួនក្នុងគុហាភ្នំប្រសិទ្ធិខេត្តសំរោងទងចាស់ ដែលជាស្រុកពញាឮ ខេត្តកណ្ដាលសព្វថ្ងៃនេះ ។ កងទ័ពតាមទៅបៀតបៀនពុំបានឡើយ។

លុះព្រះបាទព្រហ្មកិល "ពញាក្រែក" សោយរាជ្យបាន២០ឆ្នាំ ទ្រង់ចូលទីវង្គត់ទៅ នាម៉ឺនសព្វមុខមន្ត្រីដឹងថា បក្សីចាំក្រុងរាជកុមារមានបុណ្យអស្ចារ្យគង់នៅភ្នំប្រសិទ្ធិក៏អញ្ជើញទ្រង់មកសោយរាជ្យសម្បត្តិតទៅ។

កាលបើបក្សីចាំក្រុងរាជកុមារបានសោយរាជ្យឡើង ទ្រង់តាំងតាគហេ និង យាយលាក់ ជាព្រះអយ្យកោ ព្រះអយ្យកាធមិ ។ ទ្រង់ឱ្យសាងប្រាសាទមួយត្រង់ទីដែលឃើញទង់ជ័យវែងលលៃ នៃកងទ័ពដែលលើកដេញតាម ដំបូងហៅថា "ប្រាសាទលលៃ" ទ្រង់ឱ្យសង់ប្រាសាទមួយត្រង់តាគហេហៅថា បាគងសិន ហៅថា "ប្រាសាទបាគង់" ដែលក្លាយមកជា

ប្រាសាទបាគង នៅខេត្តសៀមរាបសព្វថ្ងៃនេះ ។ ទ្រង់ឱ្យសាងប្រាសាទមួយទៀតនៅក្រោល គោរបស់តាគហេ ហៅថា ប្រាសាទបាគោ ខេត្តសៀមរាបសព្វថ្ងៃនេះ ។ ទ្រង់ឱ្យសាងព្រះវិហារមួយ និងព្រះពុទ្ធ បាទមួយនៅអាសន្នទុក្ខ លើកតាម៉ឹងជាចៅហ្វាយស្រុករក្សាទីនោះ ។ទ្រង់ឱ្យសាងវិហារមួយតំកល់ព្រះពុទ្ធបដិមាមួយ

ព្រះអង្គត្រង់ទីដែលដោតមែកជ្រៃធ្វើសម្រប គឺទីដែលតាគហេតើនទ្រង់សួរពីសព្វហ្វូងសត្វស្នានថាកងទ័ពនោះ ហៅថា "វត្តវិហារសួរ" ទើបមាននាមថា "វត្តវិហារសួរ" ជាបូជនីយដ្ឋានដ៏សក្តិសិទ្ធិដរាបមកដល់សព្វថ្ងៃនេះ ។ ឯតាគហេ និង យាយលាក់នោះ លុះចាស់ជរា ទទួលមរណភាពតាមលំដាប់គ្នាទៅព្រះរាជាទ្រង់ឱ្យធ្វើបុណ្យរំលាយសពហើយទ្រង់ឱ្យយកធាតុតាគហេ នៅបញ្ចុះនៅទីដែលផ្សងមិនឱ្យមានមូស ទើបទីនោះមានឈ្មោះថា "ទួលគហេ" នៅតំបន់រកាកោង ស្រុកមុខកំពូល ខេត្តកណ្តាលសព្វថ្ងៃនេះ ។ ឯធាតុយាយលាក់ ទ្រង់ឱ្យយកទៅបញ្ចុះនៅប្រាសាទបាគោ ក្នុងខេត្តសៀមរាប ព្រោះភូមិនោះជាទីភូមិរបស់គាត់រស់នៅ ។